**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**លេខៈ ០៣ ក.ជ.ក.ក.**

*ភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧*

# ប្រកាស
# ស្តីពី
# ការបង្កើតអនុគណៈកម្មការពលកម្មកុមារ
# និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត
# មកលើកុមារ

## ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យរបស់សម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា

- បានឃើញព្រះរាជក្រម លេខ នស-រកម-០១៩៦-១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

- បានឃើញអនុក្រឹត្យ លេខ៨៣ អនក្របក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុម

- ប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ

- បានឃើញអនុស្សរណៈនៃការយោគយល់រវាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងអង្គការពលកម្មអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៧

## សម្រេច

**ប្រការ ១**

បង្កើតអនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារក្នុងគោលបំណងធានាកិច្ចអនុវត្តន៏ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើគោលនយោបាយទាំងឡាយ និងកម្មវិធីដែលទាក់ទងទៅនឹងពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ។

**ប្រការ ២**

អនុគណៈកម្មការនេះនឹងបំពេញមុខងារជាក្រុម ការងារជាតិពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារនៅក្នុងប្រទេសកម្ពុជា ។

**ប្រការ ៣**

អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារមានភារៈកិច្ចដូចតទៅ :

- ធ្វើការពិគ្រោះយោបល់លើប្រភេទ និងទំហំ នៃសកម្មភាពដែលត្រូវអនុវត្តក្នុង គំរោងកម្មវិធីជាតិពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ដោយផ្អែកលើគោលនយោបាយ និងបទប្បញ្ញត្តិជាតិ ដែលពាក់ព័ន្ធ ។
- ជ្រើសរើសកម្មវិធីសកម្មភាព ដែលស្នើឡើងដោយបណ្តាស្ថាប័នរដ្ឋាភិបាល អង្គការ សមាគមក្រៅរដ្ឋាភិបាលក្នុងស្រុក ដើម្បីស្វែងរកការជួយឧបត្ថម្ភគាំទ្រពីអង្គការភ្នាក់ងារ ឬឯកត្តជនផ្តល់ជំនួយនានា ក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិស្តីពី ការលុបបំបាត់ពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមក លើកុមារ ។
- ផ្តល់ព័ត៌មាន និងយុត្តិកម្ម ស្តីពីកម្មវិធី និងថវិកាតាមកាលកំណត់ច្បាស់លាស់ និងតាមការស្នើសុំរបស់អង្គការ ភ្នាក់ងារ ឬឯកត្តជនផ្តល់ជំនួយនានា ។
- ពិនិត្យឡើងវិញនូវរាល់កម្មវិធី ដែលកំពុងដំណើរការក្នុងក្របខ័ណ្ឌ នៃកម្មវិធីជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមក លើកុមារក្នុងបរិបទ កម្មវិធីជាតិទាំងមូល ។
- ធ្វើការពិភាក្សា និងសម្របសម្រួលរាល់សកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហាពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ដោយសហការជាមួយអ្នកដើរតួនាទីសំខាន់ៗក្នុងបញ្ហាពលកម្មកុមារ ។
- វាយការណ៍ជាប្រចាំជូនទៅក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្តីពីគោលនយោបាយកម្មវិធី និងពតិមានដែលទាក់ទងទៅនឹងបញ្ហាពលកម្មកុមារ ។

**ប្រការ ៤**

សមាសភាព នៃអនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមាររួមមាន :

| | | |
|---|---|---|
| (i) | ឯកឧត្តម រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | ជាប្រធាន |
| (ii) | តំណាង ក្រសួងមហាផ្ទៃ | ជាសមាជិក |
| (iii) | តំណាង ក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| (iv) | តំណាង ក្រសួងកិច្ចការនារី | ជាសមាជិក |
| (v) | តំណាង អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| (vi) | តំណាង ក្រសួងសុខាភិបាល | ជាសមាជិក |
| (vii) | តំណាង ក្រសួងយុត្តិធម៌ | ជាសមាជិក |
| (viii) | តំណាង កាកបាទក្រហមកម្ពុជា | ជាសមាជិក |
| (ix) | តំណាង សមាគមនិយោជក | ជាសមាជិក |
| (x) | តំណាង សហជីពកម្មករ | ជាសមាជិក |
| (xi) | តំណាង ២រូប នៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក | ជាសមាជិក |
| (xii) | តំណាង ផ្នែកពលកម្មកុមារ | ជាសមាជិក |

**ប្រការ ៥**

តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ និង អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងបណ្តាឯកត្តជនដែលចាប់អារម្មណ៍អាចចូលជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការអញ្ជើញរបស់អនុគណៈកម្មការ ។

**ប្រការ ៦**

អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗមកលើកុមារមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានឈ្មោះថាផ្នែកពលកម្មកុមារ ចំណុះក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ។

**ប្រការ ៧**

តួនាទី និង ភារៈកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នឹងត្រូវកំណត់ដោយអនុគណៈកម្មការ ពលកម្មកុមារ និង ទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ។

**ប្រការ ៨**

អនុគណៈកម្មការស្តីពីពលកម្មកុមារមានថវិកាមួយដោយឡែក ដែលបានមកពីការជួយឧបត្ថម្ភគាំទ្រ

ដោយអង្គការភ្នាក់ងារ ឬឯកត្តជនផ្តល់ជំនួយនានាហើយ ដែលបច្ចុប្បន្ននេះជាឧបសម្ព័ន្ធថវិការបស់ផ្នែកពលកម្មកុមារដែលឧបត្ថម្ភគាំទ្រដោយអង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ។

**ប្រការ ៩**

អនុគណៈកម្មការកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។

**ប្រការ ១០**

អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារមានបទបញ្ជាផ្ទៃក្នុងដោយឡែករបស់ខ្លួន ។

**ប្រការ ១១**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ**

**ប្រធាន**

**ស៊ុយ សែម**

**ចំឡងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាពតិមាន"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- កាលវប្បវត្តិ
- ឯកសារ